**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ...៣៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## វិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ ០១/នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ. បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៨ ។

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវវិធាន ផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

អនុក្រឹត្យនេះ មានគោលបំណងបង្កើនផលិតភាព និងសេវាកម្មព្រៃឈើ ធានាដល់ការរក្សាការពារគម្របព្រៃឈើ និងផ្គត់ផ្គង់ឈើសម្រាប់តម្រូវការប្រើប្រាស់ទូទៅ ស្របតាមគោលនយោបាយ និងផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ។

## ជំពូកទី ២

## ស្ថាប័ន និង អាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវ

**មាត្រា ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចលើការគ្រប់គ្រង ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដូចខាងក្រោម ÷

- ចេញប្រកាសកំណត់ ឬបដិសេធ ឬរំសាយតំបន់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ តាមសំណើរបស់រដ្ឋបាលព្រៃឈើ
- ផ្តល់ការអនុញ្ញាតជូនរដ្ឋបាលព្រៃឈើ ក្នុងការចុះកិច្ចព្រមព្រៀងជាមួយនឹងសហគមន៍មូលដ្ឋានសហគមន៍ព្រៃឈើ ឬបុគ្គលជាលក្ខណៈគ្រួសារ ក្នុងការប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

- សហការ ឬសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីជំរុញការគ្រប់គ្រង និងប្រើប្រាស់ដីព្រៃ របស់រដ្ឋ សម្រាប់ដាំឈើ ឱ្យមានប្រសិទ្ធភាព ។

**មាត្រា ៤ .-**

រដ្ឋបាលព្រៃឈើមានតួនាទី ពង្រឹងការអនុវត្តច្បាប់ បច្ចេកទេស វាយតម្លៃនូវរាល់សកម្មភាពដាំឈើ និងវាយតម្លៃការប្រមូលផលឈើ ដែលត្រូវដាំគ្រប់ប្រភេទ ដើម្បីធានាដល់ការប្រើប្រាស់ធនធានព្រៃឈើ និងផលិតផលព្រៃដែលត្រូវដាំ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានភារកិច្ចដូចខាងក្រោម ÷

- ផ្តល់លិខិតអនុញ្ញាតឱ្យដាំឈើ លើដីព្រៃរបស់រដ្ឋ
- សិក្សាវាយតម្លៃ និងកំណត់តំបន់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ
- លើកសំណើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចេញប្រកាសកំណត់ ឬបដិសេធ ឬរំសាយតំបន់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ
- ចុះហត្ថលេខាជាមួយសហគមន៍មូលដ្ឋាន សហគមន៍ព្រៃឈើ ឬបុគ្គលជាលក្ខណៈគ្រួសារ លើកិច្ចព្រមព្រៀង ផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ
- ពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងព្រៃដាំ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត កិច្ចព្រមព្រៀង លើដំណើរការដាំឈើ
- សម្របសម្រួលជាមួយស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធ ក្នុងការផ្តល់សិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋ សម្រាប់ដាំឈើ
- សម្របសម្រួល និងដោះស្រាយទំនាស់ ដែលអាចកើតមាន ក្នុងអំឡុងពេលដំណើរការអនុវត្តកិច្ចព្រមព្រៀង
- ផ្តល់សេវាកម្មបច្ចេកទេសលើការងារដាំឈើ ។

## ជំពូកទី ៣
## លក្ខខណ្ឌ និង នីតិវិធី នៃការស្នើសុំ និងការសម្រេច ផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

**មាត្រា ៥ .-**

ផ្ទៃដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងចំណាត់ថ្នាក់ណាមួយ ជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងបានចុះបញ្ជិកានៅរដ្ឋបាលព្រៃឈើស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ។

**មាត្រា ៦ .–**

ការដាំដើមឈើនៅលើដីព្រៃរបស់រដ្ឋ អាចធ្វើឡើងដោយ ÷

- រដ្ឋបាលព្រៃឈើ
- សហគមន៍ព្រៃឈើ
- រដ្ឋបាលព្រៃឈើដោយមានការចូលរួម ពីសហគមន៍មូលដ្ឋាន ឬ ផ្នែកឯកជន
- ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារ ។

**មាត្រា ៧ .–**

រាល់សំណើសុំដាំឈើលើដីព្រៃរបស់រដ្ឋនីមួយៗ រដ្ឋបាលព្រៃឈើត្រូវពិនិត្យវាយតម្លៃ និងលើកយោបល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងសម្រេច ដោយផ្អែកលើលទ្ធភាពដីព្រៃរបស់រដ្ឋ ស្របទៅតាមលក្ខណៈវិនិច្ឆ័យដូចតទៅ÷

- តំបន់ដីព្រៃ ដែលងាយរងគ្រោះដោយសារគ្រោះធម្មជាតិ ទឹកជំនន់ រាំងស្ងួត និង ខ្យល់ព្យុះ
- តំបន់ដីព្រៃរេចរឹល ភ្នំរេចរឹល ព្រៃត្រូវភ្លើងឆេះ ឬ ទីវាលរហោស្ថានដែលមិនទាន់មានការអភិវឌ្ឍ
- តំបន់ដីព្រៃដែលត្រូវស្តារព្រៃឈើឡើងវិញ
- តំបន់ដីព្រៃបម្រុងទុកសម្រាប់ដាំឈើឡើងវិញ
- តំបន់ដីព្រៃការពារការហូរច្រោះដី
- តំបន់ដីព្រៃការពារប្រភពទឹក និង រក្សានិយតកម្មប្រភពទឹក
- តំបន់ដីព្រៃអតីតព្រៃសម្បទាន ឬ តំបន់ដីសម្បទាន ដែលត្រូវបានដកហូតជាសម្បត្តិរដ្ឋវិញ
- ស្ថានីយ៍ដាំឈើរបស់រដ្ឋ
- តំបន់ដីព្រៃផ្សេងៗទៀត ដែលមានសក្តានុពលសមប្រកប សម្រាប់តែការដាំដុះដើមឈើឡើងវិញ ។

ដំណើរការពិនិត្យ និង វាយតម្លៃលើសំណើនីមួយៗ ត្រូវមានការពិគ្រោះយោបល់ ជាមួយអាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ។

**មាត្រា ៨ .–**

ការស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ អាចនឹងប្រព្រឹត្តទៅក្រោមរូបភាពខាងក្រោម ÷

-តាមការអំពាវនាវរកដៃគូ អភិវឌ្ឍដាំឈើលើដីព្រៃរបស់រដ្ឋ ស្របតាមទីតាំង ទំហំ ស្ថានភាពភូមិសាស្ត្រ ដែលនឹងត្រូវកំណត់ក្នុងប្រកាសស្តីពី ការបង្កើតផ្ទៃដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

-តាមការធ្វើសំណើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ស្នើសុំសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ តាមរយៈរដ្ឋបាលព្រៃឈើ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានភ្ជាប់មកជាមួយ នូវឯកសារពាក់ពន្ធ័ផ្សេងទៀតតាមការកំណត់របស់រដ្ឋបាលព្រៃឈើ ។

**មាត្រា ៩ ._**

ការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ធ្វើឡើងដោយរដ្ឋបាលព្រៃឈើដោយមានការចូលរួមពី ផ្នែកឯកជន ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

ការផ្តល់សិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ធ្វើឡើងរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន សហគមន៍ព្រៃឈើ ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយត្រូវចុះកិច្ចព្រមព្រៀងដាំឈើ លើដីព្រៃរបស់រដ្ឋ ជាមួយរដ្ឋបាលព្រៃឈើ ។

រាល់ការដាំដើមឈើលើដីព្រៃរបស់រដ្ឋ តម្រូវឱ្យមានលិខិតអនុញ្ញាតដាំឈើ ចេញដោយរដ្ឋបាលព្រៃឈើ ។

សម្រាប់គោលដៅនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្តល់ព័ត៌មានអំពីការអនុញ្ញាតនេះ ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាល់មុនដំណាច់ឆ្នាំនីមួយៗ។

**មាត្រា ១០ ._**

សហគមន៍មូលដ្ឋានដែលស្នើសុំសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ចាំបាច់ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ។ សហគមន៍នីមួយៗត្រូវមានការទទួលស្គាល់ពីអាជ្ញាធរដែនដី ។

ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវបានផ្តល់អាទិភាពចំពោះសហគមន៍ ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារកំពុងរស់នៅ ក្នុង ឬក្បែរតំបន់ព្រៃដែលបានស្នើសុំ និងមានការទទួលស្គាល់ពីអាជ្ញាធរដែនដី ។

តំណាងសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ ឬបុគ្គលជាលក្ខណៈគ្រួសារ ដែលស្នើសុំដាំឈើលើដីព្រៃរបស់រដ្ឋ ត្រូវមានសញ្ជាតិខ្មែរ មានសមត្ថភាព និងមាននីតិភាពតាមច្បាប់ ដើម្បីទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំ ឈើ ។

ផ្នែកឯកជន ដែលមានបំណងស្នើសុំសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវមានទីស្នាក់ការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសមត្ថភាពហិរញ្ញវត្ថុ បច្ចេកទេស ហើយបានចុះបញ្ជិកា និងទទួលស្គាល់ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ច នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ១១ ._**

ផលប្រយោជន៍ដែលទទួលបានពីការដាំឈើ លើដីព្រៃរបស់រដ្ឋ ត្រូវធ្វើការបែងចែករវាង រដ្ឋ និងអ្នកទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដូចមានចែងនៅក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## កិច្ចព្រមព្រៀងផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

**មាត្រា ១២ ._**

ខ្លឹមសារ និងលក្ខខណ្ឌអប្បបរមានៃកិច្ចព្រមព្រៀង ផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ អនុវត្ត

ចំពោះរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីផ្នែកឯកជន និងរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន យ៉ាងហោចណាស់ត្រូវមានចែងពី ៖

- កាលបរិច្ឆេទនៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ និង សុពលភាពនៃកិច្ចព្រមព្រៀង
- ការកំណត់ទីតាំង និងទំហំផ្ទៃដី ដែលត្រូវផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដោយមាន ផែនទីបញ្ជាក់និយាមកាច្បាស់លាស់
- ប្រភេទដើមឈើដែលត្រូវដាំ និងវិធីសាស្ត្រវក្ខវប្បកម្មដែលត្រូវអនុវត្ត
- ការប្រមូលផល និងការដាំឈើឡើងវិញ នៅខួបលើកក្រោយ១ទៀត
- ការអធិប្បាយពីសិទ្ធិ និងការទទួលខុសត្រូវរបស់រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លក្ខខណ្ឌនៃការបែងចែកផលប្រយោជន៍
- ការអធិប្បាយពីកាតព្វកិច្ចរបស់អ្នកទទួលសិទ្ធិ ក្នុងការកសាង និងអនុវត្តគម្រោងផែនការគ្រប់គ្រងព្រៃដាំ
- ការត្រួតពិនិត្យ និងរាយការណ៍
- ការកំណត់លក្ខខណ្ឌផ្សេងទៀតដែលចាំបាច់ ដើម្បីធានាដល់ដំណើរការគ្រប់គ្រង ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ឱ្យមានចីរភាព និងប្រសិទ្ធភាព ។

គំរូកិច្ចព្រមព្រៀង ផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣ .-**

អ្នកទទួលសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ អាចស្នើសុំបន្តកិច្ចព្រមព្រៀងបាន ដោយស្នើសុំជាលាយលក្ខណ៍អក្សរ ជូនរដ្ឋបាលព្រៃឈើ មុនពេលកិច្ចព្រមព្រៀងផុតសុពលភាព ដើម្បីលើកសំណើ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ សម្រេច ។

**មាត្រា ១៤ .-**

ការព្យួរ ការបញ្ឈប់ ការបញ្ចប់មុនកាលកំណត់ ការលុបចោលកិច្ចព្រមព្រៀង និងការដកហូតសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ រវាងរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីផ្នែកឯកជន ដោយសារការរំលោភលក្ខខណ្ឌកំណត់ក្នុងកិច្ចព្រមព្រៀង ឬដើម្បីបម្រើផលប្រយោជន៍សាធារណៈ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ត្រូវសម្រេចដោយរាជរដ្ឋាភិបាល ។

ការព្យួរ ការបញ្ឈប់ ការលុបចោលកិច្ចព្រមព្រៀង និងការដកហូតសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ រវាងរដ្ឋបាលព្រៃឈើដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ដោយសារការអនុវត្តពុំបានត្រឹមត្រូវតាមកិច្ចព្រមព្រៀង ត្រូវសម្រេចដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មុនដំណាច់ឆ្នាំនីមួយៗ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្តល់ព័ត៌មានអំពីការសម្រេចនេះ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទទួលសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ

**មាត្រា ១៥ .-**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើមានសិទ្ធិ អភិវឌ្ឍ ប្រើប្រាស់ លក់ និង ចែកចាយផលិតផលរបស់ខ្លួនបាន ស្របតាមកិច្ចព្រមព្រៀងជាមួយរដ្ឋបាលព្រៃឈើ ឬជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១៦ .-**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ មិនមានសិទ្ធិ ÷

- លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឱ្យខ្ចី បញ្ចាំ ឬផ្ទេរ ដីព្រៃរបស់រដ្ឋ ទោះតាមរូបភាពណាក៏ដោយ
- រុករករ៉ែគ្រប់ប្រភេទ ក្នុងដែនដីព្រៃរបស់រដ្ឋ
- ប្រើប្រាស់សម្រាប់ធ្វើស្រែចំការកសិកម្ម ឬសាងសង់លំនៅឋាន ក្រៅពីការដាំឈើបង្កើតជាព្រៃឡើយ ។

**មាត្រា ១៧ .-**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើមានកាតព្វកិច្ចដូចតទៅ ÷

- រៀបចំផែនការគ្រប់គ្រងព្រៃដាំដោយចីរភាព ស្របតាមការណែនាំរបស់រដ្ឋបាលព្រៃឈើ
- អនុវត្តដំណើរការដាំដុះ និង គ្រប់គ្រងព្រៃដាំដោយចីរភាព ស្របតាមច្បាប់ លិខិតបទដ្ឋាន និង កិច្ចព្រមព្រៀង
- គោរព និងអនុវត្តតាមច្បាប់ លិខិតបទដ្ឋានបច្ចេកទេស និងតាមការណែនាំរបស់រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១៨ .-**

អ្នកទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ដែលបានជួបប្រទះនូវការរំលោភ ឬបទល្មើសព្រៃឈើជាក់ស្តែង ក្នុងតំបន់ដីព្រៃរបស់រដ្ឋ ត្រូវរាយការណ៍ជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬអាជ្ញាធរមានសមត្ថកិច្ចដែល

នៅជិតបំផុត ។ ក្នុងករណីនេះ អ្នកទទួលបានសិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និងបញ្ជូនទៅមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាបន្ទាន់ ដើម្បីចាត់ការតាមនីតិវិធី ។

## ជំពូកទី ៦
## ផែនការគ្រប់គ្រងព្រៃដាំ

**មាត្រា ១៩ .-**

ការគ្រប់គ្រងព្រៃដាំប្រកបដោយចីរភាព និងប្រសិទ្ធភាព ទាមទារឱ្យមានការធ្វើផែនការគ្រប់គ្រងចាំបាច់ទៅតាមកម្រិត ទំហំ និងពេលវេលា ។ ផែនការគ្រប់គ្រងព្រៃដាំត្រូវមានពីរកម្រិតគឺ ÷

- ផែនការមេសម្រាប់គ្រប់គ្រងតំបន់ ដែលបានទទួលសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ
- ផែនការសកម្មភាពប្រចាំឆ្នាំ ។

អ្នកដែលទទួលបានសិទ្ធិប្រើប្រាស់ ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ត្រូវរៀបចំផែនការគ្រប់គ្រងព្រៃដាំទាំងពីរកម្រិតខាងលើ ឱ្យស្របទៅតាមគោលការណ៍បច្ចេកទេស បទប្បញ្ញត្តិនានា សម្រាប់គ្រប់គ្រងព្រៃឈើដោយចីរភាព ហើយអាចជួលសេវាកម្មបច្ចេកទេស ឬស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលព្រៃឈើ និងត្រូវដាក់ជូនផែនការគ្រប់គ្រងព្រៃដាំទៅរដ្ឋបាលព្រៃឈើ ដើម្បីពិនិត្យ សម្រេច ។

**មាត្រា ២០ .-**

ផែនការគ្រប់គ្រងព្រៃដាំ ត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀង ផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ដាំឈើ ។ ផែនការគ្រប់គ្រងព្រៃដាំ ត្រូវបានពិនិត្យឡើងវិញ ដោយរដ្ឋបាលព្រៃឈើរៀងរាល់ ០៥( ប្រាំ) ឆ្នាំម្តង ឬ មុនរយៈពេលនេះប្រសិនបើចាំបាច់ ។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងព្រៃដាំ ត្រូវមានការចូលរួមពីភាគីនៃកិច្ចព្រមព្រៀង ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ២១ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ